# ផូស៊ីលនៅភ្នំកង់វ៉ា

ភ្នំកង់វ៉ា ជាស្ថានីយផូស៊ីលសត្វសមុទ្រមួយ ដែលក្រុមការងារបានទៅដល់កាលពីឆ្នាំ ២០១៨ និង២០១៩។ ភ្នំនេះស្ថិតនៅក្រុងសិរីសោភណ្ឌ ខេត្តបន្ទាយមានជ័យ មានចំណុចនិយាមការ X277482-Y1508050។ យើងអាចធ្វើដំណើរពីទីរួមខេត្តបន្ទាយមានជ័យឆ្ពោះទៅកាន់ខេត្តឧត្តរមានជ័យតាមផ្លូវជាតិលេខ៥៦ ចម្ងាយ៥គីឡូម៉ែត្រ បត់ឆ្វេងទៅកាន់ភ្នំកង់វ៉ា ចម្ងាយ២.៥គីឡូម៉ែត្រ។ តំបន់ភ្នំនេះមានសក្តានុពលសម្រាប់ការអភិវឌ្ឍន៍លើវិស័យទេសចរណ៍ ដ្បិតទីតាំងមានព្រះវិហារព្រះពុទ្ធសាសនា រូងភ្នំ ប្រាសាទបុរាណ និងជាកន្លែងដែលបានរកឃើញផូស៊ីលផងដែរ។ ក្នុងអត្ថបទនេះនឹងបង្ហាញអំពីលទ្ធផលជាបឋម នៃរបកគំហើញផូស៊ីលនៅតំបន់ភ្នំកង់វ៉ា ថាតើមានពពួកផូស៊ីលអ្វីខ្លះដែលរកឃើញ? និងមានអាយុកាលនៅក្នុងស័កណាខ្លះ?

លក្ខណៈភូមិសាស្ត្រ ភ្នំកង់វ៉ាជាប្រភេទភ្នំថ្មកំបោរដែលចាក់បង្គរជាស្រទាប់ៗ ខ្លះជាដីជាគ្រួស ដីខ្មៅ ឬថ្មផ្សេងៗជាដើម ដែលប្រែប្រួលទៅតាមបរិស្ថានធម្មជាតិ(រូបលេខ១)។ ភ្នំនេះមានកម្ពស់ប្រមាណ៧០ម៉ែត្រ ធៀបនឹងនីវ៉ូទឹកសមុទ្រ។ បើយោងតាមផែនទីភូគព្ភសាស្ត្រនៃព្រះរាជាណាចក្រកម្ពុជា ទីតាំងភ្នំនេះមានអក្សរសំគាល់ PLS មានន័យថាជាភ្នំថ្មកំបោរដែលមានអាយុកាលក្នុងសម័យ Permian (២៥១-២៩៩លានឆ្នាំ) ដែលស្ថិតនៅក្នុងស័កទី១ ហៅថា Paleozoic។[៧] បើយើងពិនិត្យនៅផ្នែកខាងកើតភ្នំ គឺមានបង្ហាញពីស្នាកស្នាមរុញឡើង នៃស្រទាប់ដីដែលមានមុំចន្លោះពី១៥ទៅ២០ដឺក្រេ។ ម្យ៉ាងទៀតនៅជ្រុងខាងកើត ជ្រុងខាងជើង និងខាងត្បូងនៃភ្នំនេះ ក៏មានការជីកកាយយកថ្មសម្រាប់តម្រូវការប្រើប្រាស់របស់មនុស្សផងដែរ។

តាមការចុះសិក្សាស្រាវជ្រាវ ជាតំណាក់កាលដំបូងរបស់ក្រុមការងារនាយកដ្ឋានបេតិកភណ្ឌ នៃក្រសួងបរិស្ថានកាលពីឆ្នាំ២០១៨-២០១៩ បានរកឃើញពពួកផូស៊ីលជាច្រើនប្រភេទដែលស្ថិតនៅលើកំពូលភ្នំ ដោយការរកឃើញនោះ ភាគច្រើនជាពពួកផូស៊ីលសត្វសមុទ្រដែលមានច្រើនក្រុមមានដូចជា ផូស៊ីលពពួកខ្ចៅ និងខ្យងពុះតាន់ច្រើនប្រទះឃើញកប់នៅក្នុងស្រទាប់ថ្ម។ ហើយពពួកនេះ យើងពុំទាន់បានធ្វើការសិក្សាលម្អិតនៅ

---

[៧] General Department of Mineral Resource,2010, Geological Map of Cambodia

អត្ថបទដោយៈ លឹម វណ្ណច័ន្ទ

ឡើយទេ ដ្បិតការសិក្សានេះត្រូវការអ្នកជំនាញខាងផ្នែកផូស៊ីល ឬជំនាញពាក់ព័ន្ធ ដើម្បីជួយសហការក្នុងការសិក្សាស្រាវជ្រាវ(រូបលេខ២-៣-៤-៥)។ រហូតមកដល់ពេលបច្ចុប្បន្នពពួកខ្ចៅ និងខ្យងសមុទ្រមានច្រើនប្រភេទ។ ក្នុងនោះយើងបានរកឃើញផូស៊ីលពពួកអាម៉ូនីត Ammonite(រូបលេខ៦-៧) ដែលពពួកនេះ ពេលខ្លះយើងមានការច្រឡំខ្លះក្នុងការចាត់ថ្នាក់ ដ្បិតពពួកនេះមានសណ្ឋានស្រដៀងៗគ្នាទៅនឹងពពួកខ្យងដែរ ដែលធ្វើឱ្យពិបាកក្នុងការចាត់ថ្នាក់ទៅតាមស័ករបស់វា ដោយពពួកអាម៉ូនីតខ្លះមាននៅស័កទី១ និងខ្លះទៀតមាននៅស័កទី២។[២] ក្រៅពីនោះយើងក៏បានប្រទះឃើញប្រភេទផ្កាថ្មមួយចំនួនដែលដុះកប់ក្នុងស្រទាប់ថ្មនៅលើកំពូលភ្នំដែលមានទំហំចន្លោះពី១០ស.ម ដល់ ១៥ ស.ម (រូបលេខ៨-១០) តែប្រភេទផ្កាថ្មទាំងនោះ យើងពុំទាន់បានធ្វើការបែងចែកទៅតាមប្រភេទវានៅឡើយទេ ដោយយើងមានការស្រពិចស្រពិលខ្លះក្នុងការបែងចែក និងម្យ៉ាងតម្រូវឱ្យមានការសិក្សាលម្អិតបន្ថែមទៀត។ ការបែងចែកប្រភេទផ្កាថ្មនេះ គឺអាស្រ័យសណ្ឋាននៃស្លាកស្នាមក្រឡា ឬស្លាកស្នាមផ្កានីមួយៗរបស់ប្រភេទផ្កាថ្មនោះ។ ដោយការប្រទះឃើញប្រភេទផ្កាថ្មខ្លះមានរាងមូល និងរាងទ្រវែង ប្រហាក់ប្រហែលនឹងផ្កាថ្មនាពេលបច្ចុប្បន្ន។ ម្យ៉ាងទៀតប្រភេទពួក Sponges ក៏បានបង្ហាញលើកំពូលភ្នំដែរ ដោយពពួកនេះមានលក្ខណៈប្រហាក់ប្រហែលផ្កាថ្មដែរ តែវាមានលក្ខណៈដូចអេប៉ុងទន់ៗ និងមានប្រហោង(រូបលេខ១១)។ ហើយពពួក Sponges នេះ គឺមានការលំបាកក្នុងការបែងចែក ដ្បិតពពួកនេះបានក្លាយជាផូស៊ីលហើយ។ ក្នុងនោះមានពពួកផ្សេងៗទៀត ដែលយើងរកឃើញ តែពុំទាន់បាកំណត់អត្តសញ្ញាណ ដោយ គ្រាន់តែយើងអាចយល់បានថាវាជាពពួកផូស៊ីល នឹងទាមទារឱ្យមានការប្រមូលយកសំណាកខ្លះៗនៃផូស៊ីលយកមកលាងសំអាត និងធ្វើការសិក្សាលម្អិតបន្ថែមទៀត ដើម្បីយល់កាន់តែច្បាស់អំពីពពួកផូស៊ីលនោះ(រូបលេខ១២-១៣)។

ជារួមកស្តុតាងដែលបានរកឃើញ និងបានបរិយាយខាងលើ គឺអាចបញ្ជាក់បានថាតំបន់ភ្នំកង់វ៉ានេះអាចធ្លាប់ជាតំបន់សមុទ្រ បើទោះបីជាមានការប្រែប្រួលជានិច្ចនៃសណ្ឋានដីក៏ដោយ។ ម្យ៉ាងទៀតយើងនឹងបន្តជម្រុញការសិក្សាស្រាវជ្រាវផូស៊ីលនៅកម្ពុជាក្នុងផ្តត់គំនិតអប់រំ ការប្រមូល និងដាក់តាំងបង្ហាញសម្រាប់សិស្សនិស្សិតនៅថ្ងៃអនាគត។ ភ្នំកង់វ៉ា

[២] Miles Kelly, 2018, 6000 Awesome Facts, P134.

*អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ*

អាចមានលក្ខណៈល្អប្រសើរសម្រាប់ជាទីតាំងបង្ហាញអំពីផូស៊ីលសត្វសមុទ្រ រូងភ្នំ និងប្រាសាទបុរាណ ព្រមទាំងមានការរៀបចំជាពត៌មានសម្រាប់ការអប់រំ និងទេសចរណ៍ផងដែរ។




ផែនទីភ្នំកង់វ៉ា



រូបលេខ១៖ ស្រទាប់ថ្មកំបោរដែលចាក់បង្គរមើលពីខាងកើតភ្នំ

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៖ ពពួកស៊ីលខ្យង ខ្ចៅកប់ក្នុងថ្មកំបោរលើកំពូលភ្នំ មានមុខកាត់ទទឹង ១០ស.ម



រូបលេខ៣៖ ផូស៊ីលពពួកខ្យង ខ្ចៅ កប់ក្នុងថ្មកំបោរលើកំពូលភ្នំ មានទំហំ៥ស.ម

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៨៖ ជាខ្ចៅដែលជាប់នឹងថ្មកំបោរមានទំហំប៉ុនខ្ចៅបច្ចុប្បន្ន



រូបលេខ២៩៖ អាចជាបំណែកខ្យងដែលកប់ជាប់ក្នុងថ្មកំបោរ ទំហំ១០ស.ម

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៦៖ អាចជាពពួក អាម៉ូនីត ទំហំ១៣ស.ម



រូបលេខ២៧៖ អាចជាខ្យង ឬអាម៉ូនីត ទំហំ ១០ស.ម

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ២៨៖ ផ្កាថ្មនៅលើកំពូលភ្នំ មានទំហំប្រមាន១៥ស.ម កប់ជាប់ក្នុងថ្ម



រូបលេខ២៩៖ ផ្កាថ្មដែលគេវាយបំបែកនៅជើងភ្នំ ក្នុងថ្មទំហំ១ម៉ែត្រ នៅជើងភ្នំ

អត្ថបទដោយ៖ លឹម វណ្ណចន្ទ័



រូបលេខ១០៖ ផ្កាថ្មនៅលើកំពូលភ្នំ ទំហំ ១០ស.ម



រូបលេខ១១៖ អាចជាពពួកផ្កាថ្ម ឬ sponges ?

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ



រូបលេខ១២ ផុស៊ីល? មានទំហំ៣០ស.ម



រូបទី១៣ ផូស៊ីល? មានទំហំ ៥ស.ម

អត្ថបទដោយ៖ លឹម វណ្ណច័ន្ទ